ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ

-លេខ ៦២ “ព” ក្រ៧

ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤

-សំណុំរឿងព្រហ្មទណ្ឌលេខ ៣១១៨

ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២៣

-សំណុំរឿងស៊ើបសួរលេខ ២២៩៣

ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៣

-សំណុំរឿងជំនុំជម្រះលេខ ៣០៥៦

ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២៣

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការសាធារណៈ នាថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៣ វេលាម៉ោង ១៤ និង៣០នាទី នៅសាលសវនាការទី៧ ដោយមានសមាសភាព៖

### ក្រុមប្រឹក្សាជំនុំជម្រះ

-លោកចៅក្រម [redacted] ជាប្រធានក្រុមប្រឹក្សា

-លោកចៅក្រម [redacted] ជាចៅក្រមប្រឹក្សា

-លោកចៅក្រម [redacted] ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

-លោក [redacted] ជាព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

-លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៣១១៨ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២៣ ដែលមានជនជាប់ចោទ៖

១. ឈ្មោះ [redacted] ពិសី ភេទប្រុស កើតថ្ងៃទី១១ ខែមករា ឆ្នាំ២000 ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ថ្នាក់ទី៣ មុខរបរជាងឡានក្រុមហ៊ុន Bridgestone ឪពុកឈ្មោះ [redacted] សារឿន “ស្លាប់” ម្តាយឈ្មោះ [redacted] សារឿន “រស់” នៅលីវ ជានីតិជន ទោសពីមុនគ្មាន។ (ក្នុងឃុំ)

ទីកន្លែងកំណើត: [redacted] ខេត្តស្វាយរៀង។

អាសយដ្ឋានបច្ចុប្បន្ន: បន្ទប់ជួល ផ្លូវលំ ភូមិប៉ប្រកខាងជើង សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

ឃាត់ខ្លួនថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២៣។

ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៤៥៩០ “ភ” ដ.ឃ.ង ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៣។ (ម១)

ដោយមានលោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

២. ឈ្មោះ [redacted] ដាវេវ ភេទប្រុស កើតថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០០១ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ថ្នាក់ទី៧ មុខរបរចុងភៅ(ភោជនីយដ្ឋានចិន តែជីង មុខព្រលានយន្តហោះភ្នំពេញ) ឪពុកឈ្មោះ [redacted] សាវុធ “រស់” ម្តាយឈ្មោះ [redacted] សោភ័ណ្ឌ “រស់” ប្រពន្ធឈ្មោះ [redacted] លីន (លែងលះ) មានកូន០១នាក់ ជានីតិជន ទោសពីមុនគ្មាន។ (ក្នុងឃុំ)

ទីកន្លែងកំណើត: [redacted] ខេត្តកំពង់ចាម។

អាសយដ្ឋានបច្ចុប្បន្ន: បន្ទប់ជួល ភូមិប៉ប្រកខាងជើង សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

ឃាត់ខ្លួនថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២៣។

ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៤៥៩១ “ភ” ដ.ឃ.ង ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៣។ (ម១)

ដោយមានលោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។



Scanned with CamScanner

ជាប់ចោទពីបទ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចបណ្តោយផ្លូវបេតុង ភូមិផ្សារទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ដាណេត ភេទស្រី កើតឆ្នាំ២000 អាសយដ្ឋានបច្ចុប្បន្នស្នាក់នៅបន្ទប់ជួល ផ្លូវលំ ភូមិផ្សារទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

**អង្គហេតុនៃរឿងមានដូចតទៅ**

កាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២៣ វេលាប្រហែលម៉ោង២០ និង៤៥នាទី ជនជាប់ចោទឈ្មោះ [redacted] ពិសី បានជិះម៉ូតូម៉ាក HONDA C125 ពណ៌ខ្មៅ ស៊េរីឆ្នាំ២០២៣ ពាក់ផ្លាកលេខ ភ្នំពេញ 1KE-9081 ទៅជួបជនជាប់ចោទឈ្មោះ [redacted] ដាវេវ នៅបន្ទប់ជួលម្តុំមុខព្រលានយន្តហោះអន្តរជាតិភ្នំពេញ ហើយបានបបួលគ្នាជិះធ្វើសកម្មភាពឆក់ទ្រព្យសម្បត្តិប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញ ដោយជនជាប់ចោទឈ្មោះ[redacted]ដាវេវ ជាបើកបរម៉ូតូអ្នកឌុប ចំណែកជនជាប់ចោទឈ្មោះ[redacted] ពិសី ជិះពីក្រោយ។ លុះជិះមកដល់ចំណុចតាមបណ្តោយផ្លូវបេតុង ភូមិផ្សារទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ក៏បានឃើញជនរងគ្រោះឈ្មោះ [redacted] ដាណេត កំពុងដើរតាមបណ្តោយផ្លូវបេតុង និងមានកាន់ទូរស័ព្ទដៃម៉ាក IPHONE XS ពណ៌ទឹកមាស ជនជាប់ចោទឈ្មោះ [redacted] ដាវេវ បានបើកម៉ូតូទៅអែបទន្ទឹមជនរងគ្រោះខាងឆ្វេងដៃ ហើយជនជាប់ចោទឈ្មោះ [redacted] ពិសី បានធ្វើសកម្មភាពឆក់ទូរស័ព្ទដៃរបស់ជនរងគ្រោះបានសម្រេច រួចជិះគេចខ្លួន។ ភ្លាមនោះជនរងគ្រោះបានស្រែកថា "ចោរៗ" ផ្អើលអោឡោឡើង ស្របពេលនោះផ្លូវតូចចង្អៀត និងមានប្រជាពលរដ្ឋច្រើន ស្រាប់តែជនជាប់ចោទទាំងពីរនាក់បានជិះម៉ូតូវ៉េចង្កូតដួលដោយខ្លួនឯង និងបានចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted] ដាវេវ និងឈ្មោះ [redacted] ពិសី រួមទាំងវត្ថុតាង យកមកប្រគល់ជូនសមត្ថកិច្ចប៉ុស្តិ៍នគរបាលរដ្ឋបាលទឹកថ្លា។

-បានឃើញ របាយការណ៍សំយោគលេខ ១៣២/២៣ រ.ប.ក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២៣ របស់អធិការដ្ឋាននគរបាលខណ្ឌសែនសុខ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៣០៣០ អ.យ.ទ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៣៨៦៨ "ឆ" ង.ជ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៣។

**នាពេលសវនាការ**

ជនជាប់ចោទឈ្មោះ [redacted] ពិសី បានឆ្លើយថា នៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោងប្រហែល២០ និង៤០នាទី ខ្លួន បានជិះម៉ូតូទៅជួបឈ្មោះ[redacted] ដាវេវ នៅផ្ទះជួលមុខប្រលានយន្តហោះ។ ពេលទៅដល់ ខ្លួន និងឈ្មោះ[redacted] ដាវេវ បានបបួលគ្នាចេញរកលុយ(ធ្វើសកម្មភាពឆក់ទ្រព្យសម្បត្តិរបស់អ្នកដទៃ)។ ខ្លួនបានឱ្យឈ្មោះ[redacted]ដាវេវ បើកបរម៉ូតូរបស់ខ្លួន ម៉ាកហុងដាឌ្រីម ស៊េរីឆ្នាំ២០២៣ ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ 1KE-9081 ហើយខ្លួនជិះនៅខាងក្រោយ។ លុះជិះទៅដល់ចំណុចមុខមន្ទីរពេទ្យរ៉ូយ៉ាល់ ពួកខ្លួនក៏បានធ្វើសកម្មភាពអែបម៉ូតូទៅក្បែរមនុស្សស្រីម្នាក់កំពុងតែដើរតាមផ្លូវចុចទូរស័ព្ទ ដោយខ្លួនជាអ្នកជិះពីក្រោយលូកដៃឆក់ទូរស័ព្ទដៃរបស់ជនរងគ្រោះ។ ពេលដែលឆក់បានហើយពួកខ្លួនជិះបានប្រហែល៥ម៉ែត្រ ក៏រអិលដួល ពេលនោះជនរងគ្រោះ និងប្រជាពលរដ្ឋបានរត់មកចាប់ពួកខ្លួន ហើយសមត្ថកិច្ចក៏ឃាត់ខ្លួនតែម្តង។ សមត្ថកិច្ចឃាត់ខ្លួនរូបខ្លួន និងឈ្មោះ[redacted] ដាវេវ ព្រមទាំងបានដកហូតមានម៉ូតូរបស់ខ្លួនផងដែរ។

ជនជាប់ចោទឈ្មោះ[redacted] ដាវេវ បានឆ្លើយថា នៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោងប្រហែល ២០និង៤០នាទី ខ្លួន និងឈ្មោះ [redacted] ពិសី បានបបួលគ្នាជិះម៉ូតូដើម្បីធ្វើសកម្មភាពឆក់ទ្រព្យសម្បត្តិរបស់អ្នកដទៃតាមដងផ្លូវ ដោយខ្លួនជាអ្នកបើកបរម៉ូតូ ចំណែកឈ្មោះ [redacted] ពិសី ជិះនៅខាងក្រោយ។ ពេលបើកបរទៅដល់ចំណុចមុខមន្ទីរពេទ្យរ៉ូយ៉ាល់ ខ្លួនក៏បានធ្វើសកម្មភាពអែបម៉ូតូទៅក្បែរជនរងគ្រោះ ហើយបានធ្វើសកម្មភាពឆក់ទូរស័ព្ទបានបានសម្រេច រួចពួកខ្លួនជិះបានប្រហែល៥ម៉ែត្រ ក៏រអិលដួល ពេលនោះជនរងគ្រោះ និងប្រជាពលរដ្ឋបានរត់មកចាប់ពួកខ្លួន ហើយសមត្ថកិច្ចក៏ឃាត់ខ្លួនតែម្តង។

ក្រឡាបញ្ជីអានកំណត់ហេតុបណ្តឹងឈ្មោះ [redacted] ណេត ដែលបានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ថា នៅយប់ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២៣ ខ្លួនបានដើរចេញពីបន្ទប់ស្នាក់នៅ ទៅទិញម្ហូបនៅម្តុំវិហារចិន(សង្កាត់ទឹកថ្លា) ពេលទិញម្ហូបរួចខ្លួនក៏ដើរត្រឡប់មកបន្ទប់ជួលវិញ ពេលដើរតាមផ្លូវខ្លួនបានកាន់ទូរស័ព្ទដៃម៉ាក IPHONE XS ពណ៌ទឹកមាស ដោយដើរតាមបណ្តោយផ្លូវបេតុង ពីទិសខាងលិចទៅទិសខាងកើត ជិតដល់បន្ទប់ជួល ស្រាប់តែមានជនជាប់ចោទចំនួន០២នាក់ ជិះម៉ូតូម៉ាកសេ១២៥ ពណ៌ខ្មៅ មកអែបទន្ទឹមខាងឆ្វេងខ្លួន រួចមនុស្សប្រុស០១នាក់(ជិះក្រោយ) បានយកដៃលូកចាប់ឆក់យកទូរស័ព្ទដៃពីខ្លួនបានសម្រេច ហើយមនុស្សប្រុស០២នាក់នោះបានបន្ថែមល្បឿនម៉ូតូទៅមុខគេចខ្លួន ភ្លាមនោះខ្លួនបានស្រែកខ្លាំងថា "ចោរ" ក៏ផ្អើលឆោឡោឡើង ដល់ប្រជាពលរដ្ឋក្បែរនោះ និងអ្នកធ្វើដំណើរតាមដងផ្លូវ ដោយផ្លូវតូចចង្អៀតមានប្រជាពលរដ្ឋធ្វើដំណើរតាមផ្លូវច្រើន ជនជាប់ចោទ០២នាក់នោះ ដែលបើកម៉ូតូគេចខ្លួន ក៏រេជ្រុលចង្កូតម៉ូតូ ដួលបោកទៅផ្លូវបណ្តាលឱ្យរបួសហូរឈាម ចំណែកទូរស័ព្ទរបស់ខ្លួន ជ្រុះខ្ទាតទៅលើផ្លូវ ហើយប្រជាពលរដ្ឋនៅកន្លែងកើតហេតុ បានជួយឃាត់ខ្លួនជនជាប់ចោទទាំង០២នាក់បានតែម្តង។ បន្ទាប់មកប្រជាពលរដ្ឋបានផ្តល់ព័ត៌មានឱ្យសមត្ថកិច្ចប៉ុស្តិ៍នគរបាលរដ្ឋបាលទឹកថ្លាចុះមកឃាត់ខ្លួនជនជាប់ចោទទាំង០២នាក់ រួមទាំងម៉ូតូម៉ាក ហុងដាឌ្រីម សេ១២៥ យកទៅធ្វើការសាកសួរ និងដាក់ពាក្យបណ្តឹងតែម្តង។ ខ្លួនសំណូមពរតុលាការផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់ និងទាមទារសំណងចំនួន ២.០០០.០០០(ពីរលាន) រៀល។

ក្រឡាបញ្ជីអានកំណត់ហេតុស្តាប់ការបំភ្លឺរបស់សាក្សីឈ្មោះ [redacted] សុវីន បានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ថា នៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោង ២០ និង៤៥នាទី មុនពេលកើតហេតុ ខ្លួនបានចេញពីសាលាមកបន្ទប់ជួល ពេលនោះប្រពន្ធខ្លួនបានទូរស័ព្ទមកប្រាប់ថា មានចោរឆក់ទូរស័ព្ទដៃនៅកន្លែងកក់សក់ ដែលប្រពន្ធខ្លួនធ្លាប់កក់សក់រាល់ដង ពេលនោះខ្លួនក៏ចេញពីបន្ទប់ជួលមកដល់កន្លែងដែលប្រពន្ធខ្លួនប្រាប់ ពេលមកដល់ស្រាប់តែឃើញចោរដែលឆក់ទូរស័ព្ទប្រពន្ធខ្លួននោះ ដួលម៉ូតូហើយមានគ្នា០២នាក់ ដោយមានប្រជាពលរដ្ឋព័ទ្ធជុំវិញ ដោយជនជាប់ចោទម្នាក់មានឈាមលើមុខ និងម្នាក់ទៀតពុំមានរបួសនោះទេអង្គុយនៅជិតគំនរខ្សាច់។

ក្រឡាបញ្ជីអានកំណត់ហេតុទទួលវត្ថុចាប់យក (១) លេខ ១២១៩ រ.វ.ត ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៣ របស់សាលាដំបូងរាជធានីភ្នំពេញ និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ រួមមាន៖[1] ម៉ូតូចំនួន ០១គ្រឿង ម៉ាកហុងដាឌ្រីម សេ១២៥ ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ 1KE-9081 (មិនប្រក្រតី)។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា តាមចម្លើយសារភាពរបស់ជនជាប់ចោទទាំងពីរខាងលើ ក៏ដូចជាអំណានចម្លើយរបស់ដើមបណ្តឹង និងសាក្សី ព្រមទាំងភស្តុតាងដែលសមត្ថកិច្ចបានដកហូត ឃើញថា ជនជាប់ចោទឈ្មោះ ឈ្មោះ [redacted] ពិសី និងជនជាប់ចោទឈ្មោះ [redacted] ដាវេវ ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ប្រាកដមែន ហេតុនេះ តំណាងអយ្យការនៅតែរក្សាបទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ៣០៣០ អ.យ.ទ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣ ទុកជាបានការដដែល និងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

## សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានការពារថា តាមចម្លើយសារភាពរបស់កូនក្តីខ្លួនទាំងពីរ ឃើញថា ពិតជាមានករណីឆក់យកទូរស័ព្ទរបស់ជនរងគ្រោះប្រាកដមែន ប៉ុន្តែនៅក្នុងសកម្មភាពនេះ កូនក្តីរបស់មិនបានបង្ករបួសដល់ជនរងគ្រោះនោះឡើយ ហេតុដូច្នេះ ការចោទប្រកាន់កូនក្តីរបស់ខ្លួន ពីបទ លួចមានស្ថានទម្ងន់ទោស តាមបញ្ញត្តិមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ នោះ មិនមានភាពត្រឹមត្រូវឡើយ។ ដូច្នេះ ខ្លួនស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះមេត្តាសម្រេចកែប្រែបទចោទប្រកាន់មកលើកូនក្តីខ្លួន ពីបទ លួចមានស្ថានទម្ងន់ទោស តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ មកជាបទ លួច តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ វិញ។

(1).ឯកសារលេខ ២ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។



Scanned with CamScanner

**សម្តីចុងក្រោយរបស់ជនជាប់ចោទ**

ជនជាប់ចោទឈ្មោះ [redacted] ពិសី បានសំណូមពរសុំតុលាការ ជួយបន្ធូរបន្ថយទោសដល់ខ្លួនផង។

ជនជាប់ចោទឈ្មោះ [redacted]ដាវេវ បានសំណូមពរសុំតុលាការ ជួយបន្ធូរបន្ថយទោសដល់ខ្លួនផង។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

**សាលាដំបូងរាជធានីភ្នំពេញ**

**យល់ឃើញថា**(2)

ក.តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៣៨៦៨ “ឆ” ដ.ង ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចបញ្ជូនទៅជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ៣១១៨ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២៣ ដែលមានជនជាប់ចោទឈ្មោះ [redacted] ពិសី ភេទប្រុស អាយុ២៣ឆ្នាំ និងឈ្មោះ [redacted]ដាវេវ ភេទប្រុស អាយុ២២ឆ្នាំ ពីបទ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចបណ្តោយផ្លូវបេតុង ភូមិផ្សារទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។(3)

ខ.អង្គហេតុកើតឡើងនៅចំណុចបណ្តោយផ្លូវបេតុង ភូមិផ្សារទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ហេតុនេះជាសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌនៃសាលាដំបូងរាជធានីភ្នំពេញ។(4)

គ.អង្គហេតុកើតឡើងកាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២៣ បើគិតរហូតមកដល់ពេលនេះ មិនទាន់ផុតអាជ្ញាយុកាលនៃបទល្មើសទេ។(5)

ឃ.បើទោះបីជាដើមបណ្តឹងឈ្មោះ [redacted] ណេត មិនមានវត្តមាន នៅចំពោះមុខអង្គសវនាការក៏ដោយ ប៉ុន្តែតំណាងអយ្យការបានធ្វើការកោះហៅគ្រប់ភាគីពាក់ព័ន្ធឱ្យចូលរួមសវនាការជាសាធារណៈនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៣ វេលាម៉ោង ១៤ និង៣០នាទី ត្រឹមត្រូវរួចរាល់ហើយ ហេតុនេះតុលាការអាចបន្តសវនាការ ដោយកំបាំងមុខដើមបណ្តឹងបាន។

ង.តាមរបាយការណ៍សំយោគលេខ ១៣២/២៣ រ.ប.ក ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២៣ របស់អធិការដ្ឋាននគរបាលខណ្ឌសែនសុខ បានធ្វើការសន្និដ្ឋានថា ឈ្មោះ [redacted] ពិសី ភេទប្រុស អាយុ២៣ឆ្នាំ និងឈ្មោះ [redacted]ដាវេវ ភេទប្រុស អាយុ២២ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើ លួចមានស្ថានទម្ងន់ទោស (ឆក់ទូរស័ព្ទដៃ) នៅចំណុចបណ្តោយផ្លូវបេតុង ភូមិផ្សារទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២៣ ប្រាកដមែន។(6)

ច.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ពិសី បានឆ្លើយថា នៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោងប្រហែល២០ និង៤០នាទី ខ្លួន បានជិះម៉ូតូទៅជួបឈ្មោះ [redacted] ដាវេវ នៅផ្ទះជួលមុខប្រលានយន្តហោះ។ ពេលទៅដល់ ខ្លួន និងឈ្មោះ [redacted] ដាវេវ បានបបួលគ្នាចេញរកលុយ(ធ្វើសកម្មភាពឆក់ទ្រព្យសម្បត្តិរបស់អ្នកដទៃ)។ ខ្លួនបានឱ្យឈ្មោះ [redacted] ដាវេវ បើកបរម៉ូតូរបស់ខ្លួន ម៉ាកហុងដាឌ្រីម ស៊េរីឆ្នាំ២០២៣ ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ 1KE-9081 ហើយខ្លួនជិះនៅខាង

---

(2).មាត្រា៣២១ មាត្រា៣២២ និងមាត្រា៣៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

(3).មាត្រា២៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

(4).មាត្រា២៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

(5).មាត្រា១០ និង១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

(6).(ឯកសារលេខ:១) របស់អធិការដ្ឋាននគរបាលខណ្ឌសែនសុខ។



Scanned with CamScanner

ក្រោយ។ លុះជិះទៅដល់ចំណុចមុខមន្ទីរពេទ្យរ៉ូយ៉ាល់ ពួកខ្លួនក៏បានធ្វើសកម្មភាពអែបម៉ូតូទៅក្បែរមនុស្សស្រីម្នាក់កំពុងតែដើរតាមផ្លូវចុចទូរស័ព្ទ ដោយខ្លួនជាអ្នកជិះពីក្រោយលូកដៃឆក់ទូរស័ព្ទដៃរបស់ជនរងគ្រោះ។ ពេលដែលឆក់បានហើយពួកខ្លួនជិះបានប្រហែល៥ម៉ែត្រ ក៏រអិលដួល ពេលនោះជនរងគ្រោះ និងប្រជាពលរដ្ឋបានរត់មកចាប់ពួកខ្លួន ហើយសមត្ថកិច្ចក៏ឃាត់ខ្លួនតែម្តង។ សមត្ថកិច្ចឃាត់ខ្លួនរូបខ្លួន និងឈ្មោះ [redacted] ដាវេវ ព្រមទាំងបានដកហូតមានម៉ូតូរបស់ខ្លួនផងដែរ។

ឆ.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ដាវេវ បានឆ្លើយថា នៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោងប្រហែល ២០និង៤០នាទី ខ្លួន និងឈ្មោះ [redacted] ពិសី បានបបួលគ្នាជិះម៉ូតូដើម្បីធ្វើសកម្មភាពឆក់ទ្រព្យសម្បត្តិរបស់អ្នកដទៃតាមដងផ្លូវ ដោយខ្លួនជាអ្នកបើកបរម៉ូរ្ត ចំណែកឈ្មោះ [redacted] ពិសី ជិះនៅខាងក្រោយ។ ពេលបើកបរទៅដល់ចំណុចមុខមន្ទីរពេទ្យរ៉ូយ៉ាល់ ខ្លួនក៏បានធ្វើសកម្មភាពអែបម៉ូតូទៅក្បែរជនរងគ្រោះ ហើយបានធ្វើសកម្មភាពឆក់ទូរស័ព្ទបានបានសម្រេច រួចពួកខ្លួនជិះបានប្រហែល៥ម៉ែត្រ ក៏រអិលដួល ពេលនោះជនរងគ្រោះ និងប្រជាពលរដ្ឋបានរត់មកចាប់ពួកខ្លួន ហើយសមត្ថកិច្ចក៏ឃាត់ខ្លួនតែម្តង។

ជ.តាមអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ណេត បានឆ្លើយថា នៅយប់ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២៣ ខ្លួនបានដើរចេញពីបន្ទប់ស្នាក់នៅ ទៅទិញម្ហូបនៅម៉ុំវិហារចិន(សង្កាត់ទឹកថ្លា) ពេលទិញម្ហូបរួចខ្លួនក៏ដើរត្រឡប់មកបន្ទប់ជួលវិញ ពេលដើរតាមផ្លូវខ្លួនបានកាន់ទូរស័ព្ទដៃម៉ាក IPHONE XS ពណ៌ទឹកមាស ដោយដើរតាមបណ្តោយផ្លូវបេតុងពីទិសខាងលិចទៅទិសខាងកើត ជិតដល់បន្ទប់ជួល ស្រាប់តែមានជនជាប់ចោទចំនួន០២នាក់ ជិះម៉ូតូម៉ាកសេ១២៥ ពណ៌ខ្មៅមកអែបទន្ទឹមខាងឆ្វេងខ្លួន រួចមនុស្សប្រុស០១នាក់(ជិះក្រោយ) បានយកដៃលូកចាប់ឆក់យកទូរស័ព្ទដៃពីខ្លួនបានសម្រេច ហើយមនុស្សប្រុស០២នាក់នោះបានបន្ថែមល្បឿនម៉ូតូទៅមុខគេចខ្លួន ភ្លាមនោះខ្លួនបានស្រែកខ្លាំងថា "ចោរ" ក៏ផ្អើលឆោឡោឡើង ដល់ប្រជាពលរដ្ឋក្បែរនោះ និងអ្នកធ្វើដំណើរតាមដងផ្លូវ ដោយផ្លូវតូចចង្អៀតមានប្រជាពលរដ្ឋធ្វើដំណើរតាមផ្លូវច្រើន ជនជាប់ចោទ០២នាក់នោះ ដែលបើកម៉ូតូគេចខ្លួន ក៏វ៉េជ្រុលចង្កូតម៉ូតូ ដួលបោកទៅផ្លូវ បណ្តាលឱ្យរបួសហូរឈាម ចំណែកទូរស័ព្ទរបស់ខ្លួន ជ្រុះខ្ទាតទៅលើផ្លូវ ហើយប្រជាពលរដ្ឋនៅកន្លែងកើតហេតុ បានជួយឃាត់ខ្លួនជនជាប់ចោទទាំង០២នាក់បានតែម្តង។ បន្ទាប់មកប្រជាពលរដ្ឋបានផ្តល់ព័ត៌មានឱ្យសមត្ថកិច្ចប៉ុស្តិ៍នគរបាលរដ្ឋបាលទឹកថ្លាចុះមកឃាត់ខ្លួនជនជាប់ចោទទាំង០២នាក់ រួមទាំងម៉ូតូម៉ាក ហុងដាឌ្រីម សេ១២៥ យកទៅធ្វើការសាកសួរ និងដាក់ពាក្យបណ្តឹងតែម្តង។ ខ្លួនសំណូមពរតុលាការផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់ និងទាមទារសំណងចំនួន ២.០០០.០០០(ពីរលាន)រៀល។

ឈ.តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] សុវីន បានឆ្លើយថា នៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោង ២០ និង៤៥នាទី មុនពេលកើតហេតុ ខ្លួនបានចេញពីសាលាមកបន្ទប់ជួល ពេលនោះប្រពន្ធខ្លួនបានទូរស័ព្ទមកប្រាប់ថា មានចោរឆក់ទូរស័ព្ទដៃនៅកន្លែងកក់សក់ ដែលប្រពន្ធខ្លួនធ្លាប់កក់សក់រាល់ដង ពេលនោះខ្លួនក៏ចេញពីបន្ទប់ជួលមកដល់កន្លែងដែលប្រពន្ធខ្លួនប្រាប់ ពេលមកដល់ស្រាប់តែឃើញចោរដែលឆក់ទូរស័ព្ទប្រពន្ធខ្លួននោះ ដួលម៉ូតូហើយមានគ្នា០២នាក់ ដោយមានប្រជាពលរដ្ឋព័ទ្ធជុំវិញ ដោយជនជាប់ចោទម្នាក់មានឈាមលើមុខ និងម្នាក់ទៀតពុំមានរបួសនោះទេអង្គុយនៅជិតគំនរខ្សាច់។

ញ.សកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ពិសី និងឈ្មោះ [redacted] ដាវេវ ដែលបានធ្វើសកម្មភាពឆក់ទូរស័ព្ទដៃរបស់ជនរងគ្រោះបានសម្រេច រួចជិះគេចខ្លួន គឺជាចេតនាទុច្ចរិត ក្នុងបំណងដកហូតយកនូវទ្រព្យសម្បត្តិរបស់អ្នកដទៃមកធ្វើជារបស់ខ្លួន។

ដ.តាមកំណត់ហេតុទទួលវត្ថុចាប់យក (១) លេខ ១២១៩ វ.វ.ត ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៣ របស់សាលាដំបូងរាជធានីភ្នំពេញ និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ រួមមាន៖[7] ម៉ូតូចំនួន ០១គ្រឿង ម៉ាកហុងដាឌ្រីមសេ១២៥ ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ 1KE-9081 (មិនប្រក្រតី)។

(7).ឯកសារលេខ ២ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។



Scanned with CamScanner

ប.តាមចម្លើយជនជាប់ចោទទាំងពីរនាក់ខាងលើ តាមអំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងតាមអំណានចម្លើយសាក្សី ព្រមទាំងរបាយការណ៍សំយោគរបស់សមត្ថកិច្ច និងភស្តុតាងផ្សេងៗទៀត មានភាពស៊ីសង្វាក់គ្នាបង្ហាញឱ្យតុលាការជឿបានថា ជនជាប់ចោទឈ្មោះ [redacted] ពិសី និងឈ្មោះ [redacted] ដាវេវ ពិតជាបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ប្រាកដមែន។

ខ.អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] ពិសី និងឈ្មោះ [redacted] ដាវេវ ដែលបានធ្វើសកម្មភាពជិះម៉ូតូឆក់ទូរស័ព្ទដៃម៉ាក IPHONE XS ពណ៌ទឹកមាស របស់ជនរងគ្រោះបានសម្រេច រួចជិះគេចខ្លួន តែត្រូវបានប្រជាពលរដ្ឋឃាត់ខ្លួនប្រគល់ឱ្យសមត្ថកិច្ច បើផ្អែកតាមធាតុនីត្យានុកូលស្របទៅនឹងបទ លួចមានស្ថានទម្ងន់ទោស បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

-មាត្រា៣៥៣ នៃក្រមព្រហ្មទណ្ឌ បានចែងថា អំពើលួច គឺជាអំពើដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិ ឬវត្ថុផ្សេងទៀតរបស់អ្នកដទៃ តាមគ្រប់មធ្យោបាយក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន។

-មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ បានចែងថា អំពើលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣(បី)ឆ្នាំ ទៅ ១០(ដប់)ឆ្នាំ ក្នុងករណី អំពើលួចនេះ ប្រព្រឹត្តឡើងមុនពេល ក្នុងពេល ឬក្រោយពេលប្រើហិង្សា។

ឍ.ជនជាប់ចោទឈ្មោះ [redacted] ពិសី ភេទប្រុស អាយុ២៣ឆ្នាំ និងឈ្មោះ [redacted] ដាវេវ ភេទប្រុស អាយុ២២ឆ្នាំ ជានីតិជនមានស្មារតីល្អ មានការយល់ដឹងខុសត្រូវច្បាស់លាស់ ហើយក៏ពុំមានសញ្ញាណណាមួយបញ្ជាក់ថាជននេះមានវិបល្លាសស្មារតីអ្វីដែរ។

ណ.អំពើដែលជនជាប់ចោទឈ្មោះ [redacted] ពិសី និងឈ្មោះ [redacted] ដាវេវ បានប្រព្រឹត្តធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយសង្គម ជាពិសេសប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់បុគ្គលឯកជន ជាអំពើដែលច្បាប់ហាមឃាត់ និងតម្រូវឱ្យផ្តន្ទាទោស។

ត.កំណត់ហេតុទទួលវត្ថុចាប់យក (១) លេខ ១២១៩ រ.វ.ត ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៣ របស់សាលាដំបូងរាជធានីភ្នំពេញ និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ រួមមាន ម៉ូតូចំនួន ០១គ្រឿង ម៉ាកហុងដាឌ្រីមសេ១២៥ ពណ៌ខ្មៅពាក់ផ្លាកលេខ ភ្នំពេញ 1KE-9081 (មិនប្រក្រតី) ជាមធ្យោបាយនៃការប្រព្រឹត្តបទល្មើស គប្បីតុលាការសម្រេចរឹបអូសចូលជាសម្បត្តិរដ្ឋ ផ្អែកតាមមាត្រា៦២ និងមាត្រា៦៣ នៃក្រមព្រហ្មទណ្ឌ។

ថ.តាមកំណត់ហេតុបណ្តឹង ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២៣ របស់ឈ្មោះ [redacted] ណេត បានទាមទារសំណង ចំនួន ២.០០០.០០០(ពីរលាន)រៀល ពីឈ្មោះ [redacted] ពិសី និងឈ្មោះ [redacted] ដាវេវ ប៉ុន្តែនៅដំណាក់កាលចៅក្រមស៊ើបសួរ ក៏ដូចជាដំណាក់កាលជំនុំជម្រះ ដើមបណ្តឹងមិនបានបង្ហាញវត្តមាននៅចំពោះមុខតុលាការនោះទេ ម្យ៉ាងនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ សមត្ថកិច្ចបានប្រគល់ទូរស័ព្ទឱ្យទៅដើមបណ្តឹងវិញរួចហើយដែរ ហេតុនេះតុលាការមិនគប្បីលើកយកករណីសំណងរដ្ឋប្បវេណីមកធ្វើការពិចារណានោះទេ។

ទ.តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋាន នៅតែរក្សាបទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ៣០៣០ អ.យ.ទ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣ ទុកជាបានការដដែល និងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ការស្នើសុំតុលាការនឹងលើកយកមកពិចារណា។

ធ.មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋាន ស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះមេត្តាសម្រេចកែប្រែបទចោទប្រកាន់មកលើកូនក្តីរបស់គាត់ ពីបទ លួចមានស្ថានទម្ងន់ទោស តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ មកជាបទ លួច តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ វិញ ការស្នើសុំតុលាការនឹងលើកយកមកពិចារណា។

ន.ជនជាប់ចោទឈ្មោះ [redacted] ពិសី និងជនជាប់ចោទឈ្មោះ [redacted] ដាវេវ បានសំណូមពរសូមឱ្យលោកចៅក្រមមេត្តាជួយបន្ធូរបន្ថយទោសដល់ខ្លួនផង ការស្នើសុំនេះតុលាការនឹងលើកយកមកធ្វើការពិចារណា។



Scanned with CamScanner

មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ពិសី ភេទប្រុស អាយុ២៣ឆ្នាំ និងឈ្មោះ [redacted] ដាវេវ ភេទប្រុស អាយុ២២ឆ្នាំ ពីបទ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចបណ្តោយផ្លូវបេតុង ភូមិផ្សារទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

## ហេតុដូច្នេះ សម្រេច

១.ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ពិសី ភេទប្រុស អាយុ២៣ឆ្នាំ និងឈ្មោះ [redacted] ដាវេវ ភេទប្រុស អាយុ២២ឆ្នាំ (មានអត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល ០៤(បួន)ឆ្នាំ ពីបទ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចបណ្តោយផ្លូវបេតុង ភូមិផ្សារទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។[8]

២.វត្ថុចាប់យកមាននៅក្នុងកំណត់ហេតុចាប់យកលេខ ១២១៩ រ.វ.ត ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៣ រួមមាន ម៉ូតូចំនួន ០១គ្រឿង ម៉ាកហុងដាឌ្រីមសេ១២៥ ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ 1KE-9081 (មិនប្រក្រតី) ត្រូវរឹបអូសចូលជាសម្បត្តិរដ្ឋ។[9]

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៣ វេលាម៉ោង១៤ និង៣០នាទីរសៀល ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ពិសី និងឈ្មោះ [redacted] ដាវេវ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ វេលាម៉ោង ០៩ និង ៣០នាទី។[10]

ទុកសិទ្ធិឧទ្ធរណ៍តាមច្បាប់។[11]

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| លោក [redacted] | | | |

**បានចតបម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃអង្គារ ១៣កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ,ថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

ថ្ងៃអង្គារ ១៣កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ,ថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

(8).មាត្រា៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

(9).មាត្រា៦២ និងមាត្រា៦៣ នៃក្រមព្រហ្មទណ្ឌ។

(10).មាត្រា៣១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

(11).មាត្រា៣៦៥, មាត្រា៣៧៥, មាត្រា៣៨១ និងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។



Scanned with CamScanner